គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី

Active People's Microfinance Institution Plc.

# របាយការណ៍ប្រចាំឆ្នាំ ២០២៤

# ANNUAL REPORT 2024

គ្រឹះស្ថានឯកជន/ Private Company

# មាតិកា


**១. សារពីអគ្គនាយក** ..... ១

**២. ប្រវត្តិសង្ខេប ទស្សនវិស័យ បេសកកម្ម ពាក្យស្លោក ក្រុមអនុវត្ត និងគោលការណ៍ណែនាំរបស់គ្រឹះស្ថាន** ..... ៣

- ក. ប្រវត្តិសង្ខេប ..... ៣
- ខ. ទស្សនវិស័យ ..... ៦
- គ. បេសកកម្ម ..... ៦
- ឃ. ពាក្យស្លោក ..... ៦
- ង. ក្រុមអនុវត្ត ..... ៦
- ច. គោលការណ៍ណែនាំ ..... ៧

**៣. ផលិតផលរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ធីវភីភល** ..... ៨

**៤. ព័ត៌មានប្រតិបត្តិការ** ..... ៩

- ក. ផលប័ត្រឥណទានសរុប (ដុល្លារអាមេរិក) ..... ៩
- ខ. ចំនួនអតិថិជន ..... ៩
- គ.ទីស្នាក់ការ និងសាខាធ្វើប្រតិបត្តិការរបស់គ្រឹះស្ថាន ..... ១០

**៥. រចនាសម្ព័ន្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ធីវភីភល ភីអិលស៊ី ប្រចាំឆ្នាំ២០២៤** ..... ១២

**៦. ក្រុមប្រឹក្សាភិបាល** ..... ១៤

**៧. គណៈគ្រប់គ្រង** ..... ១៥

- ក. គណៈគ្រប់គ្រងជាន់ខ្ពស់ ..... ១៥
- ខ. គណៈគ្រប់គ្រងនាយកដ្ឋានប្រតិបត្តិការ ..... ១៦

**៨. សកម្មភាពមនុស្សធម៌ អប់រំ សកម្មភាពផ្សេងៗរបស់គ្រឹះស្ថាន**..........................១៧

**ក. សកម្មភាពមនុស្សធម៌**..........................១៧

- កាកបាទក្រហមកម្ពុជា..........................១៧
- ការបរិច្ចាគឈាមសង្គ្រោះជីវិត..........................១៧
- ការចូលរួមឧបត្ថម្ភ ជូនដល់អត្តពលិកកីឡាករ កីឡាការនីពិការភាព..........................១៨
- ការឧបត្ថម្ភ ថវិកា និងសម្ភារះផ្សេងៗ ជូនដល់ទូកចែវនាវី..........................១៨

**ខ. សកម្មភាពអប់រំ**..........................១៩

- ការឧបត្ថម្ភថវិកាជូនដល់សាលា CIESF Leaders Academy..........................១៩
- វគ្គបណ្តុះបណ្តាស្តីពី "ជំនាញត្រិះរិះពិចារណា និងការដោះស្រាយបញ្ហា"..........................១៩

**គ. សកម្មភាពផ្សេងៗ**..........................២០

- កម្មវិធីលៀងសាយភោជនជាមួយដៃគូសហការឆ្នើម..........................២០
- ការប្រកួតកីឡាប្រចាំឆ្នាំលើកទី០៨..........................២១
- កម្មវិធីជប់លៀងបុគ្គលិកប្រចាំឆ្នាំ..........................២១
- ពានរង្វាន់ Fastest Growing Microfinance Cambodia ២០២៤..........................២២
- ពានរង្វាន់ "Quality Choice Prize ២០២៤"..........................២៣

**៩. របាយការណ៍ហិរញ្ញវត្ថុ សម្រាប់ដំណាច់ឆ្នាំ២០២៤**..........................២៤

# ១. សារពីអគ្គនាយក




តាងនាមឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី និងក្រុមប្រឹក្សាភិបាល ខ្ញុំបាទមានកិត្តិយស និងសេចក្តីសោមនស្សរីករាយ សូមធ្វើការបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំ២០២៤របស់គ្រឹះស្ថាន។

ស្របតាមទស្សនៈវិស័យ និងបេសកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ និងបង្កើនជីវភាពរបស់ប្រជាជនកម្ពុជា គ្រឹះស្ថានយើងខ្ញុំបាននៅតែបន្តផ្តល់ឥណទានខ្នាតតូច មធ្យម និងបង់រំលស់ផលិតផលយានយន្ត គ្រឿងអេឡិចត្រូនិច ជាដើម ដែលបានជួយសម្រួលដល់ការបង្កើនមុខរបរនិងមធ្យោបាយធ្វើដំណើរផងដែរ។សមិទ្ធិផលសំខាន់ៗដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល សម្រេចបានគួរឱ្យកត់សម្គាល់ដើម្បីឈរជើងយ៉ាងរឹងមាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា គឺយើងបានបង្កើនទ្រព្យសកម្មរបស់ខ្លួនរហូតដល់ ៥០៥.៨១៣.៤៧៨ ដុល្លារអាមេរិក។

ស្ថានភាពមិនទាន់មានសុវត្ថិភាព និងស្ថេរភាពច្បាស់លាស់នៃសេដ្ឋកិច្ចពិភពលោក ទាំងក្នុងតំបន់ និងបណ្តាប្រទេស គ្រឹះស្ថានយើងខ្ញុំបាននិងកំពុងយកចិត្តទុកដាក់ខ្ពស់លើការអនុវត្តតាមបទប្បញ្ញត្តិប្រុងប្រយ័ត្នសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានដូចជា ប្រកាសស្តីពីអនុបាតសាធនភាព ដោយគ្រឹះស្ថានរក្សាបាន ២៥% ។ គ្រឹះស្ថានក៏នៅតែបន្តរៀបចំឥណទានឡើងវិញជូនអតិថិជនដែលបានស្នើសុំ និងអនុវត្តស្របតាមសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជានិងជាគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ។ ការអនុវត្តលើអភិបាលកិច្ចល្អ និងការគ្រប់គ្រងផ្ទៃក្នុង យើងមានប្រព័ន្ធគ្រប់គ្រងដែលប្រកបដោយប្រសិទ្ធិភាពទៅតាមតួនាទីភារកិច្ច ជាពិសេសទៀតនោះ យើងមានគណៈកម្មការកម្រិតក្រុមប្រឹក្សាភិបាលចំនួនបីគឺ គណៈកម្មការសវនកម្ម គណៈកម្មការគ្រប់គ្រងហានិភ័យក្នុង និងគណៈកម្មការតែងតាំង និងអត្ថប្រយោជន៍ដែលដឹកនាំដោយអភិបាលឯករាជ្យ។

ខណៈពេលដែលគ្រឹះស្ថានកំពុងរីកចម្រើនជាបន្តបន្ទាប់ និងស្ថានភាពពិភពលោកប្រែប្រួលទៅរកបច្ចេកវិទ្យាឌីជីថល ការពង្រឹង និងការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិកគ្រប់ផ្នែកទាំងអស់ គឺពិតជាសំខាន់។គ្រឹះស្ថាននៅតែបន្តខិតខំផ្តល់ឱកាសឲ្យបុគ្គលិកទាំងអស់ក្នុងការទទួលបានការបណ្តុះបណ្តាលទាំងក្នុងនិងក្រៅស្ថាប័នដើម្បីពង្រឹងសមត្ថភាពក្នុងការបន្តការរីកចម្រើនជាមួយស្ថាប័ន។គ្រឹះស្ថានបានសហការជាមួយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា វិទ្យាស្ថានធនាគារនិងហិរញ្ញវត្ថុ និងស្ថាប័នដទៃទៀតក្នុងការផ្តល់វគ្គបណ្តុះបណ្តាលទៅតាមមុខជំនាញផ្សេងៗ។ការយកចិត្តទុកដាក់លើមុខងារត្រួតពិនិត្យផ្ទៃក្នុង គ្រឹះស្ថានបានបញ្ជូលបុគ្គលិកទៅសិក្សាស្វែងយល់បន្ថែមលើការអនុវត្ត និងការគ្រប់គ្រងមុខងារសវនកម្មផ្ទៃក្នុងឲ្យមានប្រសិទ្ធិភាព ការធ្វើសវនកម្មផ្ទៃក្នុង និងការគ្រប់គ្រងលើការអនុវត្តឲ្យបានល្អបំផុតនិងការអនុលោមតាមច្បាប់បទប្បញ្ញត្តិជាដើម។យ៉ាងណាមិញដើម្បីគាំទ្រលើការផ្តល់សេវាឥណទានជូនអតិថិជនឲ្យកាន់តែប្រសើរឡើង គ្រឹះស្ថានបានផ្តល់វគ្គបណ្តុះបណ្តាលដល់បុគ្គលិកដូចជា ការផ្តល់ឥណទានប្រកបដោយទំនួលខុសត្រូវ ការដោះស្រាយបញ្ហា និងឥរិយាបទក្នុងការបំពេញការងារប្រកបដោយសុជីវធម៌និងវិជ្ជាជីវៈ។

ដើម្បីគាំទ្រដល់ការបង្កើនការប្រើប្រាស់ប្រាក់រៀល ស្របតាមគោលនយោបាយ បទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជាគ្រឹះស្ថានសម្រេចបាន១០%នៃឥណទានសរុបដែលគិតជាទឹកប្រាក់មានចំនួន៤៧.៣២១.២៩០ដុល្លារអាមេរិក សមមូលនឹងរូបិយប័ណ្ណខ្មែររៀលគឺមានចំនួន ១៩០.៤៦៨.១៩២ ពាន់រៀល។

សរុបលទ្ធផលក្នុងបំណាច់ឆ្នាំ២០២៤ គ្រឹះស្ថានសម្រេចបានប្រាក់ចំណេញចំនួន ២៥.៩៧៩.៦១៤ ដុល្លារអាមេរិក ជាមួយនឹងទ្រព្យសកម្មចំនួន ៥០៥.៨១៣.៤៧៨ ដុល្លារអាមេរិក។
បើប្រៀបធៀបទៅឆ្នាំ២០២៣គ្រឹះស្ថានបានបង្កើនទ្រព្យសកម្មចំនួន១៨%។ការរីកចម្រើននេះគឺបានមកពីការជឿទុកចិត្តពីសំណាក់អតិថិជនគ្រប់រូប និងការខិតខំប្រឹងប្រែងរបស់បុគ្គលិកគ្រប់ជាន់ថ្នាក់។

ជាចុងបញ្ចប់ខ្ញុំបាទជំនួសមុខក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំជាន់ខ្ពស់របស់គ្រឹះស្ថាន សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគណៈគ្រប់គ្រងនិងបុគ្គលិករបស់អាក់ទីវភីភលទាំងអស់ដែលបានខិតខំប្រឹងប្រែងពីកម្លាំងកាយចិត្តបំពេញតួនាទីភារកិច្ចរៀងៗខ្លួនបានយ៉ាងល្អរហូតទទួលបានភាពជោគជ័យគួរឲ្យកត់សម្គាល់ ហើយសូមការព្យាយាមប្រឹងប្រែងនេះនៅតែបន្តដើម្បីផ្តល់សេវាកម្មដ៏ល្អប្រសើរជូនអតិថិជនគ្រប់ៗគ្នា។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណផងដែរចំពោះ ភាគទុនិក ក្រុមប្រឹក្សាភិបាល អតិថិជន រាជរដ្ឋាភិបាល ជាពិសេសធនាគារជាតិនៃកម្ពុជាដែលគាំទ្រ និងផ្តល់ដំបូន្មានល្អជារៀងរហូតមក។

**KAZUNORI KAWAI**

**សមាជិកក្រុមប្រឹក្សាភិបាល/អគ្គនាយក**

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេក់ទីវភីភល ភីអិលស៊ី**

## ២. ប្រវត្តិសង្ខេប ទស្សនៈវិស័យ បេសកកម្ម ពាក្យស្លោក ក្រមអនុវត្ត និងគោលការណ៍ណែនាំរបស់គ្រឹះស្ថាន

### ក. ប្រវត្តិសង្ខេប

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី ហៅកាត់ថា(អេភី) បានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដែលមានលេខអាជ្ញាប័ណ្ណ ០០០០៩៤២៩ ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០១១ និងទទួលអាជ្ញាប័ណ្ណអចិន្ត្រៃយពីធនាគារ ជាតិនៃកម្ពុជា (NBC) ដើម្បីធ្វើប្រតិបត្តិការជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ រៀងមក។ បច្ចុប្បន្នគ្រឹះស្ថាន មានចំនួន ២៩ សាខា៖



**២០១៤**

- បង្កើតសាខាខណ្ឌសែនសុខ

**២០១៥**

- បង្កើនដើមទុនពី៥.០០១.៨០០ ដុល្លារអាមេរិក ដល់ ៨.៥០១.៨០០ ដុល្លារអាមេរិក

**២០១៦**

- បង្កើនដើមទុនពី ៨.៥០១.៨០០ ដុល្លារអាមេរិកដល់ ១០.០០១.៨០០ ដុល្លារអាមេរិក
- បង្កើតសាខាខេត្តបាត់ដំបង និងសាខាខេត្តកំពង់ចាម

**២០១៧**

- ផ្លាស់ប្តូរទីតាំងទីស្នាក់ការកណ្តាលថ្មីដែលមានអាសយដ្ឋាននៅអាគារលេខ៥៨ ផ្លូវលេខ២១៤ កែងនឹង ផ្លូវ១១៣ ភូមិ៤ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ
- បង្កើតសាខា ខេត្តកណ្តាល សាខាខេត្តតាកែវ និងសាខាខណ្ឌទួលគោក

**២០១៨**

- បង្កើតសាខាខណ្ឌមានជ័យ ខណ្ឌច្បារអំពៅ ខណ្ឌជ្រោយចង្វា ខេត្តបន្ទាយមានជ័យ និងខេត្តកំពង់ស្ពឺ

**២០១៩**

- បង្កើតសាខាខេត្តត្បូងឃ្មុំ និងសាខាខណ្ឌព្រែកព្នៅ

**២០២០**

- បង្កើតសាខាខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តក្រចេះ និងខេត្តរតនៈគីរី
- បង្កើនដើមទុនពី១០.០០១.៨០០ ដុល្លារអាមេរិក ដល់ ២០.០០០.០០០ ដុល្លារអាមេរិក

**២០២១**

- បង្កើតសាខា ស្រុកបារាយណ៍ ឃុំបល្ល័ង្គ (ខេត្តកំពង់ធំ), សាខាខេត្តព្រះវិហារ ,សាខាខេត្តឧត្តរមានជ័យ, សាខាខណ្ឌដង្កោ, សាខាខណ្ឌពោធិ៍សែនជ័យ ,សាខាខេត្តកំពត, សាខាក្រុងប៉ោយប៉ែត, សាខាខេត្តស្វាយរៀង, សាខាស្រុកពាមរក៍ ឃុំព្រែកខ្សាយ ខ(ខេត្តព្រៃវែង)

**២០២៣**

- បង្កើនដើមទុនពី២០.០០០.០០០ ដុល្លារអាមេរិក ដល់៥០.០០០.០០០ដុល្លារអាមេរិក









**ខ. ទស្សនៈវិស័យ**

យើងមានបំណងក្លាយទៅជាគ្រឹះស្ថានហិរញ្ញវត្ថុមួយឈានមុខគេ តាមរយៈការផ្តល់សេវាកម្មល្អប្រសើរ និងរីកចម្រើនប្រកបដោយស្ថេរភាព។

**គ. បេសកកម្ម**

យើងធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា តាមរយៈការចូលរួម និងផ្តល់នូវឥណទានដោយប្រកាន់ខ្ជាប់ភាពជាដៃគូនៃអាជីវកម្មហិរញ្ញវត្ថុ ។

**ឃ. ពាក្យស្លោក**

យើងស្តាប់លោកអ្នកគិតជាមួយលោកអ្នកដើម្បីបង្កើតដំណោះស្រាយដ៏ល្អបំផុតសម្រាប់ភាពជោគជ័យរបស់លោកអ្នក ។

## ង. ក្រមអនុវត្ត

-**ការជៀសវាងបំណុលលើសលប់៖** គ្រឹះស្ថានផ្តល់ឥណទានតាមលទ្ធភាពសងរបស់អតិថិជន និងរកវិធីដើម្បីបញ្ចៀសបំណុលលើសលប់តាមដែលអាចធ្វើបាន។

-**ក្រមសីលធម៌របស់បុគ្គលិក៖** គ្រឹះស្ថានមានការបណ្តុះបណ្តាលបន្ថែម និងប្រកាន់ខ្ជាប់នូវឥរិយាបថប្រកបដោយការគោរព ក្រមសីលធម៌ខ្ពស់ ចំពោះអតិថិជនគ្រប់មជ្ឈដ្ឋានពីបុគ្គលិកគ្រប់លំដាប់ថ្នាក់។

-**សេរីភាពក្នុងការជ្រើសរើស៖** អតិថិជនមានសិទ្ធិជ្រើសរើសផលិតផល ឬសេវាកម្មរបស់គ្រឹះស្ថានដែលសមស្របនឹងមុខរបរ និងតម្រូវការ។

-**យន្តការឆ្លើយតបចំពោះមតិយោបល់៖** គ្រឹះស្ថានទទួលយកនូវមតិយោបល់ ដើម្បីស្តាប់នា និងឆ្លើយតបឲ្យបានសមរម្យបំផុត។

## ច. គោលការណ៍ណែនាំ

១ ផ្ដល់សេវាហិរញ្ញវត្ថុជូនប្រជាពលរដ្ឋទូទៅដោយមិនប្រកាន់វណ្ណៈ

២ ផ្ដល់សេវាហិរញ្ញវត្ថុដែលមានលក្ខណៈបត់បែន និងងាយស្រួលជាងគេ

៣ ប្ដេជ្ញាគោរព និងឲ្យតម្លៃអតិថិជនរបស់ខ្លួនជាអាទិភាព

៤ ប្ដេជ្ញាប្រកាន់ខ្ជាប់នូវអត្តចរិកនិងស្តង់ដារការងារដើម្បីធានាបាននូវភាពជឿជាក់

៥ ប្ដេជ្ញាផ្ដល់សេវាកម្ម និងទំនាក់ទំនងល្អបំផុតដល់ប្រជាពលរដ្ឋគ្រប់រូប

៦ ជាគ្រឹះស្ថានរៀនសូត្រដែលមានការផ្លាស់ប្ដូរ និងការចែករំលែកនូវព័ត៌មានសមស្របដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍

## ៣. ផលិតផលរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេក់ធីបភីអិល

- ១ កម្ចីរហ័ស
- ២ កម្ចីបង់រំលស់ម៉ូតូ
- ៣ កម្ចីបង់រំលស់គ្រឿងអេឡិចត្រូនិច
- ៤ កម្ចីប្រើប្រាស់ទូទៅ
- ៥ កម្ចីបង់រំលស់រថយន្ត
- ៦ កម្ចីបង់រំលស់ដី
- ៧ កម្ចីបង់រំលស់គ្រឿងចក្រកសិកម្ម
- ៨ ឥណទាន A-Plus

## ៤ .ព័ត៌មានប្រតិបត្តិការ

### ក. ផលប័ត្រឥណទានសរុប (ដុល្លារអាមេរិក)




### ខ. ចំនួនអតិថិជន

| | |
|---|---|
| ២០២៤ | ២៣៦,៣៦៥ |
| ២០២៣ | ១៩៩,៨៧៤ |
| ២០២២ | ១៧៨,១៦២ |
| ២០២១ | ១៣៩,៨៧៩ |
| ២០២០ | ១១៣,១០៤ |



# គ. ទីស្នាក់ការ និងសាខាធ្វើប្រតិបត្តិការរបស់គ្រឹះស្ថាន





# ៥. រចនាសម្ព័ន្ធរបស់គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ អាក់ទីចតីគល ប្រចាំឆ្នាំ២០២៤






**នាយកដ្ឋានរដ្ឋបាល**

# ៦. ក្រុមប្រឹក្សាភិបាល



លោក Ryosuke KATAOKA
ប្រធានក្រុមប្រឹក្សាភិបាល



លោក Tatsuhiro KURIHARA
សមាជិកក្រុមប្រឹក្សាភិបាល



លោក Kazunori KAWAI
សមាជិកក្រុមប្រឹក្សាភិបាល/ អគ្គនាយក



លោក Masao SUGITA
សមាជិកក្រុមប្រឹក្សាភិបាល



លោក ម៉ាឡាយ ខេមសូលី
សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ/
ប្រធានគណៈកម្មាធិការគ្រប់គ្រងហានិភ័យ



លោកស្រី ស៊ិន ស៊ីឡែន
សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ/
ប្រធានគណៈកម្មាធិការសវនកម្ម

# ៧. គណៈគ្រប់គ្រង

## ក. គណៈគ្រប់គ្រងជាន់ខ្ពស់



លោក Kazunori KAWAI
អគ្គនាយក



លោក សុខ ពិសោ
នាយកប្រតិបត្តិ ប្រតិបត្តិការ



លោកស្រី ជា ទិតា
នាយិកានាយកដ្ឋានប្រតិបត្តិតាម



លោក ថៃ វុទ្ធី
នាយកនាយកដ្ឋានសវនកម្មផ្ទៃក្នុង



កញ្ញា សេង ចាន់ថា
នាយិកានាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ



លោក Ishikawa MASAKI
នាយកនាយកដ្ឋានរដ្ឋបាល



លោក Ono GOTO
នាយកនាយកដ្ឋានគាំទ្រការគ្រប់គ្រងប្រមូលឥណទាន

## ខ. គណៈគ្រប់គ្រងនាយកដ្ឋានប្រតិបត្តិការ



## ៨. សកម្មភាពមនុស្សធម៌ អប់រំ និងសកម្មភាពផ្សេងៗរបស់គ្រឹះស្ថាន

### ក. សកម្មភាពមនុស្សធម៌

### កាកបាទក្រហមកម្ពុជា

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល បានឧបត្ថម្ភថវិកាជូនកាកបាទក្រហមកម្ពុជាក្នុងឱកាសខួបទី១៦១ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម៨ឧសភាឆ្នាំ២០២៤ក្នុងគោលបំណងចូលរួមបន្តគាំទ្រដល់ការផ្តល់សេវាសុខុមាលភាពសង្គម សកម្មភាពមនុស្ស ធម៌បន្តពង្រឹងភាពធន់សហគមន៍ជួយសម្រាលទុក្ខលំបាកដោះស្រាយបញ្ហាប្រឈមនានាជូនប្រជាពលរដ្ឋរងគ្រោះនិងការងារសុខាភិបាល ក្រោមប្រធានបទ «រួមគ្នាជាមួយកាកបាទក្រហមកម្ពុជា ដើម្បីសហគមន៍មានសុខភាពល្អ និងមានភាពធន់នឹងអាកាសធាតុ»។



### ការបរិច្ចាគឈាមសង្គ្រោះជីវិត

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល បានចូលរួមបរិច្ចាគឈាមក្រោមប្រធានបទ «រួមគ្នាសង្គ្រោះជីវិត»រៀបចំឡើងដោយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជារួមជាមួយធនាគារជាតិនៃកម្ពុជាសមាគមធនាគារនៅកម្ពុជានិងសហភាពសហព័ន្ធយុវជនកម្ពុជារាជធានីភ្នំពេញ។យុទ្ធនាការនេះរៀបចំឡើងក្នុងគោលបំណងប្រមូលឈាមដោយស្ម័គ្រចិត្តជូនដល់មជ្ឈមណ្ឌលជាតិផ្តល់ឈាមដើម្បីសង្គ្រោះជីវិតនិងលើកកម្ពស់ការយល់ដឹង អំពីសារៈសំខាន់នៃការបរិច្ចាគឈាម ។



## ការចូលរួមឧបត្ថម្ភ ជូនដល់អត្តពលិកកីឡាករ កីឡាការនីពិការភាព

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល បានចូលរួមឧបត្ថម្ភ ដល់កីឡាករក្នុងព្រឹត្តិការណ៍ប្រកួតជើងឯកអត្តពលកម្មជនពិការកម្ពុជាលើកទី៥។ ព្រឹត្តិការណ៍នេះធ្វើឡើងដើម្បីពង្រឹងសមត្ថភាពរបស់កីឡាករ កីឡាការនីពិការភាព ដើម្បីប្រមូលផ្តុំជំនាញគ្រប់គ្រង និងលើកកម្ពស់កីឡាករ។ ក្នុងឱកាសនេះគ្រឹះស្ថានក៏បានផ្តល់កាដូអនុស្សាវរីយ៍លើកទឹកចិត្តដល់កីឡាករ កីឡាការនីផងដែរ។

"កីឡានាំមកនូវសុខភាព"



## ការឧបត្ថម្ភថវិកា និងសម្ភារៈផ្សេងៗ ជូនដល់ទូកចែវនារី

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល បានឧបត្ថម្ភ អាវយឺត មួក ភេសជ្ជៈ គ្រឿងឧបភោគបរិភោគ និងថវិកាមួយចំនួន ជូនដល់ ទូកចែវនារី ព្រះពៃស្រពណ៌ ក្រោមការដឹកនាំដោយ លោក ជូវ គឹមស៊ីន អភិបាលស្រុកជលគិរី នឹងគណៈកម្មការដឹកនាំទូក ដើម្បីចូលរួមអបអរសាទរ ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក។



## ខ. សកម្មភាពអប់រំ

### ការឧបត្ថម្ភថវិកាជូនដល់សាលា CIESF Leaders Academy

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី និងម្ចាស់ភាគហ៊ុនពីប្រទេសជប៉ុន បានឧបត្ថម្ភថវិកាជូនដល់សាលា CIESF Leaders Academy ក្រោមការស្វាគមន៍យ៉ាងកក់ក្តៅពីលោកគ្រូនាយកសាលាផ្ទាល់។ ការឧបត្ថម្ភនេះធ្វើឡើងដើម្បីចូលរួមចំណែកក្នុងការទិញរថយន្តជួយសម្រួលដល់ការធ្វើដំណើររបស់សិស្សានុសិស្សទាំងអស់។

អាក់ទីវភីភល នឹងចូលរួមក្នុងការជួយអភិវឌ្ឍប្រទេសកម្ពុជាតាមរយៈការលើកកម្ពស់ស្តង់ដានៃការអប់រំ ហើយនឹងនៅតែបន្តយ៉ាងសកម្មក្នុងសកម្មភាពសង្គម និងវិស័យអប់រំបន្ថែមទៀតនាពេលអនាគត (កុមារជាទំពាំងស្នងឫស្សី)។



### វគ្គបណ្តុះបណ្តាស្តីពី "ជំនាញត្រិះរិះពិចារណា និងការដោះស្រាយបញ្ហា"

អាក់ទីវភីភល បានសហការជាមួយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា(CMA) ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ជំនាញត្រិះរិះពិចារណា និងការដោះស្រាយបញ្ហា" ក្រោមអធិបតីភាព លោកជំទាវ ឌិត នីតា ប្រធានក្រុមប្រឹក្សាភិបាលសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។

ការបណ្តុះបណ្តាលគឺជាប្រធានបទមួយដែលគ្រឹះស្ថានបានយកមកដាក់ ដើម្បីអភិវឌ្ឍធនធានមនុស្សនៅក្នុងប្រតិបត្តការអាជីវកម្មរបស់ខ្លួនដោយថ្មីៗនេះគ្រឹះស្ថានបានរៀបចំវគ្គបណ្តុះបណ្តាលដល់បុគ្គលិកចំនួន ៣៣រូប ដោយការបណ្តុះបណ្តាលនេះអាចជួយពង្រីកការយល់ដឹង និងពង្រឹងសមត្ថភាពបន្ថែមក្នុងការអនុវត្តការងារប្រកបដោយប្រសិទ្ធភាពខ្ពស់។



### គ. សកម្មភាពផ្សេងៗ

### កម្មវិធីលៀងសាយភោជនជាមួយដៃគូសហការឆ្នើម

គ្រឹះស្ថាន បានប្រារព្ធកម្មវិធីលៀងសាយភោជន ដើម្បីថ្លែងអំណរគុណដល់ដៃគូសហការ ព្រមទាំងមានការប្រគល់ពានរង្វាន់ជូនដល់ដៃគូសហការឆ្នើមប្រចាំឆ្នាំ និងបង្កើនទំនាក់ទំនងឲ្យកាន់តែល្អបន្ថែមទៀតក្នុងការសហការជាដៃគូអាជីវកម្ម។ គ្រឹះស្ថានមានការរីកចម្រើនឡើងដោយសារការចូលរួមគ្រោមគ្រែងពីសំណាក់ដៃគូសហការ និងអតិថិជនទាំងអស់ ដែលតែងតែគាំទ្រនូវសេវាកម្មពីគ្រឹះស្ថានយើងខ្ញុំ។ យើងខ្ញុំសង្ឃឹមថា ដៃគូសហការទាំងអស់ និងអតិថិជន



## ការប្រកួតកីឡាប្រចាំឆ្នាំលើកទី០៨

គ្រឹះស្ថានតែងតែរៀបចំព្រឹត្តិការណ៍ប្រកួតកីឡាប្រចាំឆ្នាំ ជារៀងរាល់ឆ្នាំ។ កម្មវិធីនេះធ្វើឡើងក្នុងគោលបំណងជួបជុំបុគ្គលិកទាំងអស់ដើម្បីបង្កើនភាពស្និទ្ធស្នាល និងសាមគ្គីភាពគ្នាជាក្រុមប្រកួតកីឡាដើម្បីទទួលបានជ័យលាភី។




## កម្មវិធីជប់លៀងបុគ្គលិកប្រចាំឆ្នាំ

ការជប់លៀងបុគ្គលិកប្រចាំឆ្នាំជាពេលវេលាមួយបង្ហាញនូវការលើកទឹកចិត្តក្នុងការបំពេញការងារបានល្អរយៈពេលពេញមួយឆ្នាំ។ មិនត្រឹមតែប៉ុណ្ណោះ គ្រឹះស្ថានបានរៀបចំជាពានរង្វាន់ដល់សាខាឆ្នើម បុគ្គលិកឆ្នើម បុគ្គលិកធ្វើការរយៈពេល៥ឆ្នាំ ១០ឆ្នាំ និងរង្វាន់អនុស្សាវរីយ៍ជាច្រើនទៀត ដើម្បីថ្លែងអំណរគុណដល់ការខិតខំប្រឹងប្រែងក្នុងការបំពេញភារកិច្ចជួយជ្រោមជ្រែងនិងរួមចំណែកឲ្យគ្រឹះស្ថានមានការរីកចម្រើន។



**ពានរង្វាន់ Fastest Growing Microfinance Cambodia ២០២៤**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអាក់ទីវភីភល ភីអិលស៊ី បានទទួលពានរង្វាន់ជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដែលមានការរីកចម្រើនលឿនជាងគេបំផុត ក្នុងឆ្នាំ២០២៤ "Fastest Growing Microfinance Cambodia 2024" ផ្តល់ជូនដោយ Global Banking & Finance Review ដែលជាស្ថាប័នត្រួតពិនិត្យជាសកលលើវិស័យធនាគារ និងហិរញ្ញវត្ថុ។

អាក់ទីវភីភល បានទទួលពានរង្វាន់ជាបន្តបន្ទាប់៖

- នៅឆ្នាំ ២០២៤ ទទួលបានពានរង្វាន់ Fastest Growing Microfinance
- នៅឆ្នាំ ២០២២ ទទួលបានពានរង្វាន់ Best Microfinance
- នៅឆ្នាំ ២០២០ ទទួលបានពានរង្វាន់ Fastest Growing Microfinance



**ពានរង្វាន់** Quality Choice Prize 2024

អាក់ទីវភីភលបានទទួលពានរង្វាន់ *"Quality Choice Prize 2024"* លំដាប់ថ្នាក់ Diamond ពីស្ថាប័ន European Society for Quality Research ( ហៅកាត់ ESQR).

ការទទួលបានពានរង្វាន់មួយនេះគឺជាការសបញ្ជាក់ឲ្យបានឃើញថា គ្រឹះស្ថានរបស់យើងខ្ញុំ ត្រូវបានទទួលស្គាល់ថាជាគ្រឹះស្ថានមួយដែលមានភាពជោគជ័យទៅលើយុត្តិសាស្រ្តនៃការគ្រប់គ្រងជំនាញវិជ្ជាជីវៈនិងក្រមសីលធម៌។លើសពីនេះទៅទៀតយើងគឺជាគ្រឹះស្ថានមួយដែលកំពុងតែមានសក្តានុពលយ៉ាងខ្លាំងលើផ្នែកសេវាកម្ម។






អាសយដ្ឋានផ្ទះលេខ៨៨ ផ្លូវលេខ២១៤ កែងផ្លូវលេខ១១៣ សង្កាត់បឹងព្រលិត
ខណ្ឌ៧មករា រាជធានីភ្នំពេញ
#88, St.214 corner St.113, Sangkat Boeng Prolit, Khan 7 Makara, Phnom Penh
www.apmfi.com.kh
/Activepeople's MFI
081 828 666/ 071 828 6666